ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣៩,៥១ ហិកតា នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៧៥/១៧ អបខ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតលេខ ៣៨៦៨ កសក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ៣៩,៥១ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជា ដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែងទំហំ ៣៨,០៤ ហិកតា និងផ្ទៃដីទំហំ ១,៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិរើងពើង ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង(២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ០៦ គ្រួសារ នៅភូមិរើងពើង ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣** : ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន ចំនួន ០៦ ក្បាលដី ជូនប្រជាពលរដ្ឋ ០៦ គ្រួសារ ស្ថិតនៅ ភូមិរើងពើង ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។



www.pheakdeylaw.com

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវុសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...ខែ...ឆ្នាំ២០១៧ ស្តីពីការកាត់ឆ្វៀលផ្ទៃដីសរុបទំហំ ៣៩,៥១ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ០៦គ្រួសារ លើផ្ទៃដីទំហំ ៣៨,០៤ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ១,៤៧ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិវាំងពើង ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ




កំពង់ស្ពឺ,ថ្ងៃទី...២៥... ខែ...ឧសភា... ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ...២៤២...ជនសស.កស្ព
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី...២៥... ខែ...ឧសភា... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ស្ពឺ

គាង់ ម៉ាឡៃ

លេខ...២៧៥/១៧ សរ... 
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី...២៥... ខែ...ឧសភា... ឆ្នាំ២០១៧
អភិបាលនៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

វ៉ី សំណាង

ឧបសម្ព័ន្ធ....... ចំណុចនិយាមកាព្រំដី ដែលស្នើសុំកាត់ចេញពីដែនដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ
ដើម្បីធ្វើប្រទានកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ០៦គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំផ្ទះជាក់ស្តែង
ស្ថិតនៅភូមិកើតកើត ឃុំស្ពះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

## តារាងចំណុចនិយាមកា

Projection UTM, Zone 48N, Datum WGS 84

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 444616 | 1260181 | 34 | 444670 | 1259598 | 67 | 444986 | 1260334 |
| 2 | 444605 | 1260151 | 35 | 444692 | 1259634 | 68 | 445000 | 1260371 |
| 3 | 444607 | 1260087 | 36 | 444709 | 1259671 | 69 | 445029 | 1260382 |
| 4 | 444608 | 1260080 | 37 | 444711 | 1259674 | 70 | 445024 | 1260400 |
| 5 | 444630 | 1260053 | 38 | 444712 | 1259728 | 71 | 445004 | 1260399 |
| 6 | 444634 | 1260012 | 39 | 444788 | 1259730 | 72 | 445000 | 1260439 |
| 7 | 444646 | 1260006 | 40 | 444818 | 1259808 | 73 | 444986 | 1260441 |
| 8 | 444682 | 1259997 | 41 | 444882 | 1259825 | 74 | 444939 | 1260455 |
| 9 | 444688 | 1259970 | 42 | 444983 | 1259846 | 75 | 444942 | 1260538 |
| 10 | 444697 | 1259890 | 43 | 445096 | 1259891 | 76 | 444965 | 1260540 |
| 11 | 444662 | 1259889 | 44 | 445050 | 1259936 | 77 | 444985 | 1260546 |
| 12 | 444624 | 1259888 | 45 | 445035 | 1259992 | 78 | 444983 | 1260562 |
| 13 | 444612 | 1259889 | 46 | 445035 | 1260010 | 79 | 445020 | 1260571 |
| 14 | 444581 | 1259886 | 47 | 445037 | 1260046 | 80 | 445022 | 1260585 |
| 15 | 444577 | 1259865 | 48 | 445041 | 1260050 | 81 | 445098 | 1260599 |
| 16 | 444572 | 1259824 | 49 | 445044 | 1260059 | 82 | 445091 | 1260622 |
| 17 | 444586 | 1259823 | 50 | 445045 | 1260074 | 83 | 445086 | 1260651 |
| 18 | 444582 | 1259802 | 51 | 445044 | 1260081 | 84 | 445085 | 1260676 |
| 19 | 444578 | 1259788 | 52 | 445005 | 1260080 | 85 | 445082 | 1260708 |
| 20 | 444573 | 1259759 | 53 | 444996 | 1260073 | 86 | 445075 | 1260741 |
| 21 | 444565 | 1259703 | 54 | 444966 | 1260065 | 87 | 445077 | 1260756 |
| 22 | 444563 | 1259684 | 55 | 444971 | 1260139 | 88 | 445069 | 1260782 |
| 23 | 444564 | 1259673 | 56 | 444960 | 1260141 | 89 | 444660 | 1260681 |
| 24 | 444560 | 1259638 | 57 | 444961 | 1260173 | 90 | 444642 | 1260502 |
| 25 | 444555 | 1259599 | 58 | 445091 | 1260237 | 91 | 444639 | 1260473 |
| 26 | 444551 | 1259556 | 59 | 445076 | 1260240 | 92 | 444637 | 1260459 |
| 27 | 444548 | 1259517 | 60 | 445060 | 1260245 | 93 | 444630 | 1260424 |
| 28 | 444560 | 1259515 | 61 | 445041 | 1260251 | 94 | 444629 | 1260379 |
| 29 | 444570 | 1259513 | 62 | 445021 | 1260254 | 95 | 444632 | 1260367 |
| 30 | 444593 | 1259513 | 63 | 445021 | 1260276 | 96 | 444636 | 1260362 |
| 31 | 444610 | 1259511 | 64 | 445023 | 1260300 | 97 | 444639 | 1260348 |
| 32 | 444657 | 1259509 | 65 | 444986 | 1260300 | 98 | 444636 | 1260304 |
| 33 | 444656 | 1259558 | 66 | 444986 | 1260317 | 99 | 444629 | 1260285 |

កំពង់ស្ពឺ,ថ្ងៃទី..២៥.. ខែ..៥..... ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ..៤៤២......ជនសស.កស្ព
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី...២៥... ខែ..៥..... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដីខេត្តកំពង់ស្ពឺ

សាយ ម៉ាំខ្មៅ

លេខ.....២៧៥/១៧.សបដ
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី...២៨... ខែ...៦...... ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

ថ្មី សំណាង